00637224

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 01 / 2011
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# អនុស្សរណៈអន្តរការិយាល័យ

ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១

ជូនចំពោះ៖ រោង ឈុង
ប្រធានអង្គភាពគាំពារជនរងគ្រោះ

តាមរយៈ៖ មន្ត្រីគ្រប់គ្រងសំណុំរឿង

មកពី៖ ប្រាក់ គឹមសាន
ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

ចម្លងជូន៖ ភាគីទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អវតក/កសចស
អង្គជំនុំជម្រះសាលាដំបូង និងការិយាល័យសហចៅក្រមស៊ើបអង្កេត

កម្មវត្ថុ៖ ដំណោះរបស់អង្គបុរេជំនុំជម្រះលើការអនុវត្តចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ៣ ដែលស្ទួនគ្នា

ឆ្លើយតបទៅនឹងអនុស្សរណៈអន្តរការិយាល័យរបស់លោក រោង ឈុង ប្រធានអង្គភាពគាំពារជនរងគ្រោះ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ដែលមានភ្ជាប់មកជាមួយនេះ អង្គបុរេជំនុំជម្រះសូមបញ្ជាក់ថា អនុលោមតាមការអនុវត្តកន្លងមករបស់សហចៅក្រមស៊ើបអង្កេត ទម្រង់ព័ត៌មានស្តីពីជនរងគ្រោះដែលស្ទួនគ្នា នឹងត្រូវចាត់ទុកដូចជាព័ត៌មានបន្ថែម។ អាស្រ័យហេតុនេះ ទម្រង់ព័ត៌មានស្តីពីជនរងគ្រោះដែលមានលេខសម្គាល់ 09-VU-02069, 08-U-02323 និង 07-U-00378 នឹងត្រូវចាត់ទុកដូចជាព័ត៌មានបន្ថែមសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែល

មានលេខសម្គាល់ 08-VU-00019 (D22/0190), 08-VU-01830 (D22/1165) និង 07-VU-00259 (D22/0622)។

ដោយផ្អែកលើព័ត៌មានដែលអង្គភាពគាំពារជនរងគ្រោះបានផ្តល់នៅក្នុងអនុស្សរណៈចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះនឹងចាត់ទុកមេធាវីតំណាងដែលបានជ្រើសតាំងដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងលិខិតប្រគល់សិទ្ធិរបស់ខ្លួន ជាអ្នកតំណាងតាមផ្លូវច្បាប់របស់ពួកគេ។ ការតែងតាំងមេធាវីដោយការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅពេលនោះត្រូវបានចាត់ទុកថាមិនទាន់មានមេធាវីតំណាង ដោយសារនៅពេលនោះមិនទាន់ដឹងថា មានការដាក់ពាក្យសុំស្ទួនគ្នានៅឡើយ ត្រូវបានចាត់ទុកជាមោឃៈ។ អាស្រ័យហេតុនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 08-VU-00019 (D22/0190) ត្រូវបានចាត់ទុកថតំណាងដោយ ម៉ុច សុវណ្ណារី, គីម ម៉េងឃី, Martine JACQUIN និង Philippe CANONNE ហើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 08-VU-01830 (D22/1165) និង 07-VU-00259 (D22/0622) ត្រូវបានចាត់ទុកថាតំណាងដោយ ឡោ ជុនធី និង Olivier BAHOUGNE។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C